# ស្ថានទូតអូស្ត្រាលី
# ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦

## ឯកអគ្គរាជទូតអូស្ត្រាលីនឹងចូលរួមពិធីសម្ពោធគម្រោងផ្លូវជនបទ ជាជំនួយរដ្ឋាភិបាលអូស្ត្រាលី ក្រោមអធិបតីភាព សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន

ក្នុងសប្តាហ៍នេះ លោកជំទាវ **អេនជេលឡា ខកខឺរ៉េន** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា នឹងធ្វើដំណើរទស្សនៈកិច្ចជាផ្លូវការលើកដំបូងទៅកាន់ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

នៅខេត្តត្បូងឃ្មុំ លោកជំទាវឯកអគ្គរាជទូតនឹងចូលរួមក្នុងកម្មវិធីសម្ពោធគម្រោងធ្វើអោយប្រសើរឡើងនូវផ្លូវជនបទដំណាក់កាលទី២ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃពុធ ក្រោមអធិបតីភាព សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។

រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ទឹកប្រាក់ចំនួន ១៨.៥២ លានដុល្លារអាមេរិកសម្រាប់គម្រោងនេះ ដែលនឹងជួយដល់ការស្តារឡើងវិញនូវផ្លូវជនបទប្រវែង១,២០០គីឡូម៉ែត្រនៅក្នុងខេត្តចំនួនដប់នៅទូទាំងប្រទេសកម្ពុជា។

គម្រោងហេដ្ឋារចនាសម្ព័ន្ធដ៏មានសារៈសំខាន់នេះ នឹងជួយធ្វើអោយប្រសើរឡើងនូវលទ្ធភាពរបស់ប្រជាជនកម្ពុជាក្នុងការទទួលបាននូវទីផ្សារ ការងារ និងសេវាសង្គមនានា។ គម្រោងនេះក៏នឹងជួយបង្កើនសុវត្ថិភាពផ្លូវថ្នល់ និងជួយគាំទ្រដល់ភាពធន់ទ្រាំទៅនឹងបម្រែបម្រួលអាកាសធាតុផងដែរ។

សហគមន៍នានាដែលស្ថិតក្នុងទីតាំងគម្រោងក៏នឹងទទួលបាននូវការបណ្តុះបណ្តាល និងការគាំទ្រលើការកាត់បន្ថយហានិភ័យនានាពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងមេរោគហ៊ីវ/អេដស៍ផងដែរ។

នៅក្នុងការធ្វើដំណើរទៅកាន់ខេត្តកំពង់ចាមនាថ្ងៃនេះ លោកជំទាវឯកអគ្គរាជទូតនឹងជួបប្រជុំជាមួយឯកឧត្តមអភិបាលខេត្ត **លន់ លឹមថៃ** ដើម្បីពិភាក្សាអំពីកិច្ចសហការគាំទ្ររបស់អូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនៅក្នុងខេត្ត។

លោកជំទាវឯកអគ្គរាជទូតក៏នឹងជួបជាមួយគ្រួសារមួយចំនួននៅក្នុងខេត្តកំពង់ចាមដែលបានតភ្ជាប់បណ្តាញទឹកស្អាត ក្រោមជំនួយរបស់មូលនីធិទឹកស្អាតអនាម័យនិងសុខភាពសង្គមស៊ីវិលអូស្ត្រាលី(Australian Civil Society WASH Fund) ផងដែរ។

កម្មវិធីជំនួយអូស្ត្រាលីបានកំពុងចូលរួមជម្រុញឲ្យមានភាពប្រសើរឡើងថែមទៀតក្នុងវិស័យសុខាភិបាលនៅក្នុងខេត្ត ដោយបានគាំទ្រដល់ការសាងសង់នូវមណ្ឌលសុខភាពចំនួន១១។

កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា ដំណាក់កាលទីពីរ CAVACII កំពុងសហការដៃគូជាមួយមន្ត្រីជំនាញថ្នាក់ខេត្ត ដើម្បីជួយជម្រុញប្រសិទ្ធិផលក្នុងវិស័យស្រូវ និងដំឡូងឈើ។

អូស្ត្រាលីបានគាំទ្រដល់ការបង្ការបទល្មើសនិងលើកកម្ពស់សុវត្ថិភាពដល់ឃុំចំនួន៣៥ ក្នុងខេត្តកំពង់ចាមតាមរយៈកម្មវិធីភាពជាដៃគូជំនួយយុត្តិធម៌សហគមន៍នៅកម្ពុជា (CCJAP)។

*សាកសួរព័ត៌មាន:* [Australian.Embassy.Cambodia@dfat.gov.au](mailto:Australian.Embassy.Cambodia@dfat.gov.au)